# ហេតុអ្វីបានជា សត្វនាគ ស្អប់សត្វគ្រុឌម្លេះ?

## ប្រវត្តិគ្រុឌស្អប់នាគ



ដកស្រង់ពីខ្សែររឿង រាមាយាណៈ ប្រវត្តិសត្វគ្រុឌ សត្វគ្រុឌមានប្រវត្តិតាំងពីយូរលង់មកហើយ ដែលសត្វនេះមានពាក់ព័ន្ធនៅក្នុងទេវកថានៃព្រហ្មញ្ញសាសនា។ សត្វគ្រុឌនេះដែរ ក៏ត្រូវបានគេចាត់ ទុកដូចជាសត្វអច្ឆរិយៈផ្សេងៗទៀត ដែលខ្មែរបុរាណបានឲ្យតម្លៃ តាំងពី ប្រមាណជាង ២ ០០០ឆ្នាំមកហើយ។ នៅក្នុងទេវកថាឥណ្ឌា មានសត្វជា ច្រើនត្រូវបានចាត់ទុកថាជាទេព ឬក៏ជាពាក់កណ្ដាលទេព ឧទាហរណ៍ដូច ពស់ ឬនាគ អណ្ដើក ខ្លាឃ្មុំ ស្វា គោ ដំរី ក្ងោក ខ្លាជាដើម។ ដូចគ្នានេះដែរ សត្វគ្រុឌ ក៏មានតួនាទីសំខាន់ក្នុងទេវកថាឥណ្ឌា ហើយត្រូវបានគេ ចាត់ ទុកថា បក្សីរាជា។ សត្វគ្រុឌ គឺជាយានជំនិះរបស់ព្រះវិស្ណុ ហើយសត្រូវ សួរពូជរបស់គ្រុឌគឺសត្វនាគ។ នៅឥណ្ឌាមានពិធីបុណ្យគោរពបូជា ដល់ គ្រុឌដែលតែងតែប្រារព្ធធ្វើឡើងនៅថ្ងៃ៥ កើត ខែស្រាពណ៍រៀងរាល់ឆ្នាំ។

រឿងនិទានទាក់ទងនឹងគ្រុឌ មហាឥស្សី កស្សបៈ មានភរិយាពីររូបគឺនាងកាទ្រុ និងនាងវីនីតា។ នាងកាទ្រុបានផ្ដល់កំណើតកូនជាសត្វពស់មានចំនួនរាប់សិបពាន់ក្បាល ហើយត្រូវបានចាត់ទុកថាបុព្វការីនៃសត្វពស់នៅលើផែនដីនេះ។ ចំណែក ឯនាងវីនីតាបានផ្ដល់កំណើតឲ្យសត្វគ្រុឌដ៏មានអំណាចឫទ្ធានុភាព។ ថ្ងៃមួយនាងកាទ្រុ និងនាងវីនីតា បានលេងល្បែងភ្នាល់គ្នាដោយទាយ ពណ៌កន្ទុយសេះក្បាល៧អាចហោះបានដែលកើតចេញពីការកូរសមុទ្រ ទឹកដោះ។ នាងកាទ្រុបានទាយថាកន្ទុយសេះមានពណ៌ខ្មៅ រីឯនាងវីនីតា ថាពណ៌ស។ ពួកគេបានភ្នាល់គ្នាថានរណាក៏ដោយឲ្យតែចាញ់ គឺត្រូវតែ បម្រើអ្នកឈ្នះ។ នាងកាទ្រុបានប្រើល្បិចបោកប្រាស់នាងវីនីតាដោយប្រើ ឲ្យកូនរបស់ខ្លួនដែលជាសត្វនាគក្លែងខ្លួនធ្វើជាកន្ទុយសេះ។ ដូច្នេះហើយ នាងវីនីតាត្រូវបម្រើនាងកាទ្រុ និងកូន។ នាងកាទ្រុ បានធ្វើបាបនាង វីនីតាយ៉ាងខ្លាំងក្លា។

ប៉ុន្តែក្រោយមកពពួកនាគថានឹងយល់ព្រមដោះលែងគ្រុឌ និងម្ដាយ ប្រសិនជាគ្រុឌអាចទៅយកទឹកអម្រឹតរបស់ព្រះឥន្ទបាន។ គ្រុឌបាន ប្រឹងប្រែងយ៉ាងខ្លាំង ហើយទីបំផុតទទួលបានទឹកអម្រឹត ហើយបានរំ ដោះខ្លួន និងម្ដាយពីទាសភាពរបស់នាគ និង

នាងកាឌ្រុ។ ក្រោយមកគ្រុឌ និងម្ដាយបានដឹងពីល្បិចនេះ ហើយបានដាក់បណ្ដាសាដល់នាង កាឌ្រុ ថារាល់កូនរបស់នាងកាឌ្រុទាំងអស់គឺត្រូវតែក្លាយទៅជាចំណីរបស់កូន ខ្លួន។




និយាយកាលដែលគ្រុឌទៅលួចយកទឹកអម្រឹតពីព្រះឥន្ទ្រ គ្រុឌបាន សំដែងឫទ្ធីចេស្ដារយ៉ាងអស្ចារ្យ និងមានភាពស្មោះត្រង់រហូតបាន ដឹង ដល់ព្រះវិស្ណុ ហើយព្រះវិស្ណុបានផ្ដល់ពរជ័យ ព្រមទាំងយកគ្រុឌធ្វើ ជាយានជំនិះរបស់ព្រះអង្គ។ អនុភាពហោះហើររបស់គ្រុឌគឺលឿនជារន្ទះ ហើយកំលាំងខ្យល់ពីស្លាបរបស់គ្រុឌគឺខ្លាំងលើព្យុះសង្ឃរានានា។ ព្រះឥន្ទ្របានមកស្កាត់ផ្លូវគ្រុឌ ប៉ុន្តែអ្នកទាំងពីរមិនប្រយុទ្ធគ្នានោះទេ ដោយ គ្រុឌសន្យាថានឹងប្រគល់ទឹកអម្រឹតដល់ព្រះឥន្ទ្រវិញ ក្រោយពេល ប្រគល់ឲ្យនាគហើយនោះ ហើយព្រះឥន្ទ្រសន្យាថានឹងធ្វើឲ្យបណ្ដាសា របស់គ្រុឌ និងម្ដាយក្លាយជាការពិត។ នៅពេលយកទឹកអម្រឹតមកដល់ មុខនាគហើយនោះ គ្រុឌបានប្រើល្បិចប្រាប់ដល់នាគថាចាំបាច់ ត្រូវធ្វើពិធី សិនមុនពេលផឹកទឹកអម្រឹតនេះ ហើយនៅពេលដែលពួកនាគកំពុងធ្វើ ពិធីនោះព្រះឥន្ទ្របានមកយកទឹកអម្រឹតទៅវិញតែកំពប់ទឹកខ្លះនៅលើស្មៅ។ នៅពេលដែលឃើញទឹកកំពប់នៅលើស្មៅហើយ ពួកនាគទាំងឡាយខំ ប្រឹងលិទ្ធទឹកអម្រិតទាំងនោះរហូតដល់អណ្ដាតប្រេះជាពីរដោយសារស្មៅរហូតដល់សព្វថ្ងៃនេះ ព្រះវិស្ណុបានផ្ដល់វេហារទាំងមូលជាទីលំនៅរបស់គ្រុឌ ហើយរៀបការគ្រុឌ ជាមួយនាងឧណាតី។ គ្រុឌ និងនាងឧណាតីមានកូនពីរនាក់គឺសម្ប៉ាទិ និងជតាយុ ដែលកូនទាំងពីរនេះមានតួនាទីផងដែរនៅ ក្នុងរឿង រាមាយាណៈ។



ដកស្រង់ពីខ្សែររឿង មហាភារតៈយុទ្ធ ក្នុងរឿងទេវកថាមួយតំណាល ថា គ្រុឌ គឺជាមនុស្សដែលមានក្បាលជាបក្សី ក្រុម គ្រុឌ មួយចំនួនមានអំណាចវេទមន្តនៃការក្រលាខ្លួនទៅជាមនុស្សនៅពេលដែលពួកគេមានបំណង ចង់មានទំនាក់ទំនងជាមួយមនុស្ស។លំនៅដ្ឋានរបស់ពួកគ្រុឌ គឺមាននៅក្នុងព្រៃនៃ simbalī ឬដើមឈើសូត្រ-កប្បាស។ នៅថ្ងៃមួយ ស្តេច គ្រុឌ មាន ស្នេហាជាមួយនឹងស្ត្រីមនុស្សលោក តំណាលគ្នា ទៅនិង ស្តេចនាគ ដែលមានអំណាចវេទមន្តនៃការក្រលាខ្លួនទៅជាមនុស្ស ដូចគ្នា។ គួបផ្សំនិងការប្រណាំងប្រជែងក្នុងរឿងនេះ ស្តេច គ្រុឌបានប្រកាសសង្គ្រាមប្រយុទ្ធនិង ស្តេចនាគ យ៉ាងខ្លាំងក្លា តែភាព ឆ្លាតវៃរបស់ស្តេចនាគបានធ្វើឲ្យសង្គ្រាមមួយនេះ មិនអាចដឹងចាញ់ឈ្នះ។ ក្រោយមក មានក្រុម តាបស កាវ៉ាប៊ី ដែល គាំទ្រ ពួកគ្រុឌ បានបង្ហើបឱ្យដឹងដោយសារសម្ងាត់ទៅពួកគ្រុឌ ដែលបានបង្រៀនពួកគ្រុឌពីរបៀបដើម្បីចាប់យកស្តេចភុជង្គនាគ ដោយកន្ទុយហើយបង្ខំឱ្យក្អួតចេញនៅដុំថ្មភ្លើងនោះ ធ្វើឲ្យពួកនាគ ហត់នឿយ និង អស់អំណាចនៃដុំភ្លើងនោះ ពួកគ្រុឌ បានចាប់ក្បាល ពួកនាគ និង សម្លាប់ចោល ។

ក្រោយ ពីពួកនាគដឹងខ្លួនថាមិនអាចប្រយុទ្ធឈ្នះ ពួកគ្រុឌ ពួកនាគ ក៏ទៅ សុំឲ្យមានការជួយ ពី ព្រះវិស្ណុ ព្រះ វិស្ណុ ក៏ស្នើឲ្យ មានការផ្អាកប្រយុទ្ធ និង ព្រមព្រៀងរវាង ស្តេច គ្រុឌ និង ស្តេច ភុជង្គនាគ ។ ក្រោយមក ព្រះវិស្ណុ សន្យាថា និងឲ្យមនុស្សលោក ដាក់ ស្តេចគ្រុឌ នៅក្នុងស្ថានភាពល្អគ្មានគូប្រៀបមួយ គឺ នៅតាមផ្នែកខាងលើសសរស្តម្ភ នៃ ដំណាក់ ឬ ព្រះវិហារ ឬ នៅពីលើលំនៅដ្ឋាន ទោះជាយ៉ាងណា ព្រះ វិស្ណុះ ក៏ ចង់ឲ្យស្តេច គ្រុឌ ធ្វើជាយាន្តជំនិះ ក្នុងការព្រមព្រៀងនេះ។ ចុង ក្រោយ ពួកគ្រុឌ ស្ថិតក្នុងចំណោមដែលត្រូវបានតែងតាំងដោយ Śakraដើម្បីការពារភ្នំ ព្រះសុមេរុ និងលំហ ពីការវាយប្រហាររបស់ពួកអសុរា។ ចំនែក ស្តេចនាគ ត្រូវបានព្រមព្រៀង ដើម្បីបង្អុលទឹកភ្លៀងដល់មនុស្សលោក ។ ចែករំលែកដោយប្អូន Chetra Sky

